# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៩៣៥ "ក្រ$_2$ ណ"

ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ៧៥៤៧

ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ៥៤០៨

ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ១៤២៥

ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជំនុំជម្រះជាអសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ០២ និង៣០នាទីរសៀល និងបន្តសវនាការ នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ០២ និង៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### មេធាវី

លោក [redacted] **បញ្ញា** មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោក [redacted] **ឡុងឌី** មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកស្រី [redacted] **ស៊ីណារេត** មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៧៥៤៧ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ធីរ៉ា** ភេទប្រុស អាយុ ២៥ឆ្នាំ កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ មុខរបរបើកឡានដឹកដំឡូង ទីកន្លែងកំណើតនៅភូមិ[redacted] ស្រុកបាភ្នំ ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ[redacted] ខេត្តប៉ៃលិន ប្រពន្ធឈ្មោះ[redacted] (លែងលះ) ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ជានីតិជន ទោសពីមុន-គ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១២៦៤៦ "ភ" ដ.ឃ.ដ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ នៅមណ្ឌលអប់រំកែប្រែទី១។

ជាប់ចោទពីបទ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ[redacted] **ម៉ូលីកា** ភេទស្រី អាយុ ១៤ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ទីលំនៅបច្ចុប្បន្នស្នាក់ [redacted] រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **វណ្ណៈ** ភេទស្រី អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរមេផ្ទះ ទីលំនៅ✓



Scanned with CamScanner

[redacted]រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

នៅក្នុងអំឡុងឆ្នាំ២០១២ ឈ្មោះ [redacted] វណ្ណៈ បានយកកូនស្រីឈ្មោះ [redacted] ម៉ូលីកា ភេទស្រី អាយុ ០៨ឆ្នាំ និងកូនប្រុសឈ្មោះ [redacted] លីមហេង ភេទប្រុស អាយុ ០៥ឆ្នាំ ទៅរស់នៅជាមួយលោកយាយឈ្មោះ [redacted] តាំងអូន នៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង។ លុះមកដល់ខែឧសភា ឆ្នាំ២០១២ ជនសង្ស័យឈ្មោះ [redacted] ជីវ៉ា ភេទប្រុស ដែលរស់នៅជាមួយយាយដែលនោះ បានចាប់រំលោភសេពសន្ថវៈលើឈ្មោះ [redacted] ម៉ូលីកា បានសម្រេចបួន ទៅប្រាំដង និងបានគម្រាមជនរងគ្រោះមិនឱ្យយករឿងនេះទៅប្រាប់យាយ។ លុះដល់ឆ្នាំ២០១៥ ខណៈពេលដែលយាយឈ្មោះ [redacted] តាំងអូន មិននៅផ្ទះ ស្រាប់តែឈ្មោះ [redacted] ជីវ៉ា បានធ្វើសកម្មភាពរំលោភលើជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា បានសម្រេចពីរដងទៀត ហើយនៅក្នុងឆ្នាំ២០១៥ ដដែលនោះ យាយឈ្មោះ [redacted] តាំងអូន ក៏បាននាំចៅៗខាងលើមករស់នៅភ្នំពេញ នៅភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ លុះមកដល់ឆ្នាំ២០២០ ឈ្មោះ [redacted] វណ្ណៈ ជាម្ដាយបានត្រឡប់មកពីធ្វើការនៅប្រទេសថៃវិញ និងបានមករស់នៅជាមួយកូនៗវិញ នៅរាជធានីភ្នំពេញ ខណៈនោះកូនស្រីឈ្មោះ [redacted] ម៉ូលីកា ក៏បានប្រាប់ម្ដាយអំពីរឿងហេតុដែលបានកើតឡើងខាងលើ បន្ទាប់មកម្ដាយឈ្មោះ [redacted] វណ្ណៈ ក៏បានដាក់ពាក្យបណ្ដឹងទៅសមត្ថកិច្ច ហើយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ សមត្ថកិច្ចក៏ឃាត់ខ្លួនឈ្មោះ [redacted] ជីវ៉ា បានតែម្ដងនៅខេត្តប៉ៃលិន។

បានឃើញ របាយការណ៍សរុបលេខ០៧២/២០២០ រ.ប.ក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្សនៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ១១១១ អ.យ.ឈ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១៧៩១ "ភ" ដ.ដ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា បានឆ្លើយនាពេលសវនាការកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ថា ខ្លួនពិតជាបានប្រព្រឹត្តកំហុសលើប្អូនជីដូនមួយឈ្មោះ [redacted] ម៉ូលីកា មែន។ ខ្លួនបានប៉ះពាល់លើឈ្មោះ [redacted] ម៉ូលីកា ចំនួនបួនលើក លើកទីមួយនៅពេលថ្ងៃ ដោយពេលនោះនៅផ្ទះមានតា និងប្អូនជីដូនមួយ ផ្ទះលើមួយជាន់មានឡៅតឿលើ លើកទីពីរ នៅពេលថ្ងៃដែរចំនួនបីដង។ ពេលខ្លួនប៉ះពាល់គាត់ហើយពុំមានកើតអីនោះទេ ហើយក៏ពុំបានគំរាមកំហែងលើក្មេងដែរ។ ម្ដាយរបស់គាត់ទើបដឹងនៅក្នុងឆ្នាំ២០២០ នេះទេ ពេលគាត់ដឹងថាកូនគាត់មានរោគស្ត្រី។ ខ្លួនពុំបានរួមភេទជាមួយក្មេងទេ។ នៅពេលនោះខ្លួនមានអាយុ ១៥ឆ្នាំ ចំណែកក្មេងស្រីមានអាយុ ៧ឆ្នាំ ពេលនោះខ្លួនបានទ្រោបពីលើនាងតែមិនបានដាក់ប្រដាប់ភេទរបស់ខ្លួនចូលទៅក្នុងប្រដាប់ភេទក្មេងទេ។ ខ្លួនបានដោះអាវស្រាតខោរបស់ក្មេង និងបានក្រាបពីលើ ដោយបានយកប្រដាប់ភេទរបស់ខ្លួនញុលៗលើក្បាលពោះរបស់ក្មេង ដោយសារពេលនោះខ្លួននៅក្មេងពុំដឹង ហើយពេលនោះខ្លួនពុំបានមើលរឿងអាសអាភាសនោះទេ និងមិនដឹងថាមានអារម្មណ៍បែបណាទេ ហើយការប្រព្រឹត្តរបស់ខ្លួនរាល់ដងពុំមានចេញទឹកកាមនោះទេ។ យាយរបស់ខ្លួនបានផ្លាស់មករាជធានីភ្នំពេញក្នុងឆ្នាំ២០១២ ខ្លួនបានធ្វើសកម្មភាពបែបនេះលើក្មេងស្រីបានម្ដង។ ខ្លួនបានជាប់ពន្ធនាគាររយៈពេល ៩ខែមកហើយ និងមានការសោកស្ដាយចំពោះសកម្មភាពរបស់ខ្លួនដែលបានប្រព្រឹត្ត និងចង់កែប្រែកំហុស។



Scanned with CamScanner

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា នៅដំណាក់កាលស៊ើបសួរថា ខ្លួនសុំបដិសេធត្រង់ចម្លើយដែលថាខ្លួនបានគំរាមជនរងគ្រោះនោះគឺខ្លួនមិនបានគំរាមនោះទេ។ កាលពីអំឡុងឆ្នាំ២០១១ មីងបង្កើតរបស់ខ្លួនឈ្មោះ [redacted] វណ្ណៈ បានយកកូនគាត់ពីរនាក់ឈ្មោះ [redacted] ម៉ូលីកា ភេទស្រី អាយុ ៨ឆ្នាំ និងឈ្មោះ [redacted] លីមហេង ភេទប្រុស អាយុ ៥ឆ្នាំ មករស់នៅជាមួយតា និងយាយឈ្មោះ [redacted] តាំងអួន ដែលពេលនោះខ្លួនកំពុងរស់នៅជាមួយតាយាយដែរ។ ហើយនៅក្នុងអំឡុងឆ្នាំ២០១១ មិនចាំថ្ងៃខែខ្លួនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើឈ្មោះ [redacted] ម៉ូលីកា បានចំនួនបីលើក នៅថ្ងៃខែខុសគ្នា(មិនចាំថ្ងៃខែ ឆ្នាំ២០១១) នៅពេលតាយាយមិននៅផ្ទះ ខ្លួនធ្វើសកម្មភាពរំលោភសេពសន្ថវៈនៅពេលដែលពួកយើងលេងបិតពួនជាមួយគ្នា(នៅពេលនោះខ្លួនមានអាយុ ១៧ឆ្នាំ) ខ្លួនបានឱ្យឈ្មោះ [redacted] ម៉ូលីកា ស្រាតសំពត់ចេញ និងឱ្យវាដេកហើយខ្លួនបានយកប្រដាប់ភេទរបស់ខ្លួនដាក់ពីលើប្រដាប់ភេទរបស់ឈ្មោះ [redacted] ម៉ូលីកា ដោយដាក់ត្រដុសៗពីលើប្រដាប់ភេទរបស់ឈ្មោះ [redacted] ម៉ូលីកា តែមិនបានចូលទេ បានរយៈពេល ប្រហែល៥នាទី ខ្លួនក៏ឈប់ ហើយក៏មិនបានចេញទឹកកាមទេ។ បន្ទាប់មកនៅឆ្នាំ២០១២ ខ្លួនបានមកធ្វើការងារនៅភ្នំពេញជាបុគ្គលិកចាក់សាំង ហើយនៅឆ្នាំ២០១២ នោះដែរ យាយរបស់ខ្លួនឈ្មោះ [redacted] តាំងអួន បានមកទិញផ្ទះ និងរស់នៅភ្នំពេញ នៅភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ ដោយនាំចៅៗ និងឈ្មោះ [redacted] ម៉ូលីកា មករស់នៅជាមួយដែរ ចំណែកខ្លួនក៏រស់នៅជាមួយយាយដែរ។ បន្ទាប់មកនៅថ្ងៃខែមិនចាំ ឆ្នាំ២០១២ វេលាម៉ោងប្រហែល ១២ថ្ងៃត្រង់ នៅពេលដែលយាយខ្លួនមិននៅផ្ទះ ខ្លួនបានហៅឈ្មោះ [redacted] ម៉ូលីកា ឡើងទៅបន្ទប់ជាន់ទី១ ហើយប្រាប់វាឱ្យស្រាតសំពត់ និងឱ្យវាដេកលើគ្រែ ហើយខ្លួនក៏ស្រាតខោ និងយកប្រដាប់ភេទរបស់ខ្លួនដាក់ត្រដុសៗលើប្រដាប់ភេទរបស់ឈ្មោះ [redacted] ម៉ូលីកា ដាក់មិនចូលបានរយៈពេលប្រហែលប្រាំនាទីមិនចេញទឹកកាមខ្លួនក៏ឈប់ទៅ។ ក្រៅពីនោះខ្លួនមិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើឈ្មោះ [redacted] ម៉ូលីកា ទៀតនោះទេ។ បន្ទាប់មកក្នុងអំឡុងឆ្នាំ២០១៣ ខ្លួនបានទៅធ្វើការងារនៅខេត្តប៉ៃលិនរហូតមកដល់បច្ចុប្បន្ន។ ពេលខ្លួនរំលោភសេពសន្ថវៈឈ្មោះ [redacted] ម៉ូលីកា ម្តងៗខ្លួនមិនដែលគំរាមកំហែងនោះទេ។ ខ្លួនសំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផងព្រោះពេលនោះខ្លួននៅក្មេងមិនបានគិតវែងឆ្ងាយ។

-ជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា បានឆ្លើយនាពេលសវនាការថា កាលពីអំឡុងឆ្នាំ២០១១ ម៉ាក់របស់ខ្លួនទៅថៃហើយបានយកខ្លួនទៅផ្ញើនៅជាមួយយាយ ពេលនោះខ្លួនមានអាយុ ៧ឆ្នាំ បានចូលរៀនហើយ ចំណែកប្អូនរបស់ខ្លួនមិនទាន់ចូលរៀនទេ។ នៅជាមួយយាយតាមានប្រុសៗតែពីរនាក់ទេ។ ឈ្មោះ [redacted] ជីវ៉ា ធ្វើសកម្មភាពរំលោភខ្លួន៥លើក មានមួយលើនៅភ្នំពេញ តែពុំចូលទេ។ ពេលនោះខ្លួនពុំបានប្រាប់អ្នកណាទេព្រោះគាត់បានគំរាមខ្លួន ហើយខ្លួនក៏មិនបានដឹងថាគាត់រំលោភដែរ។ ពេលនោះខ្លួនពាក់រ៉ូប ដោយពេលនោះគាត់បានយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន តែមិនដឹងថារយៈពេលប៉ុន្មាននាទីនោះទេ ពេលនោះក៏មានការឈឺចាប់ និងមានឈាមនៅប្រដាប់ភេទតែមិនហ៊ានប្រាប់យាយទេព្រោះឈ្មោះ [redacted] ជីវ៉ា គាត់គំរាម។ ក្នុងឆ្នាំ២០១៣ ខ្លួនមករស់នៅជាមួយម៉ាក់វិញ មូលហេតុដែលម៉ាក់ដឹងដោយសារខ្លួនមានរោគស្ត្រី ទើបប្រាប់ម៉ាក់នៅក្នុងខែកញ្ញា ឆ្នាំ២០២០ ហើយម៉ាក់ក៏បានជូនទៅពេទ្យ។ ខ្លួនមករស់នៅក្នុងឆ្នាំ២០១៧ ចំណែកការធ្លាក់សគឺតាំងពីឆ្នាំ២០១៤។ នៅពេលដែលគាត់ធ្វើសកម្មភាពរំលោភខ្លួនយាយមិននៅផ្ទះទេ ចំណែកតាគាត់ដេកឈឺនៅផ្ទះ។ តាំងពីឆ្នាំ២០១៤ មកមិនដែលមានអ្នកណាមកប៉ះពាល់ខ្លួនរបស់ខ្លួនទៀតទេ។

-អំណានចម្លើយរបស់ឈ្មោះ [redacted] ម៉ូលីកា នៅដំណាក់កាលស៊ើបសួរថា កាលពីអំឡុងឆ្នាំ២០១២ ខ្លួនមានអាយុ ៧ឆ្នាំ ម្តាយរបស់ខ្លួនបានយកខ្លួន និងប្អូនប្រុសឈ្មោះ [redacted] លីមហេង អាយុ ៥ឆ្នាំ ទៅផ្ញើយាយបង្កើតរបស់ខ្លួនឈ្មោះ [redacted] តាំងអួន នៅខេត្តព្រៃវែង ព្រោះម្តាយឪពុកខ្លួនបានលែងលះគ្នា ហើយម្តាយរបស់ខ្លួនត្រូវទៅធ្វើការនៅប្រទេសថៃ។ ពេលនោះខ្លួនរស់នៅជាមួយយាយតាបងប្អូនជីដូនមួយឈ្មោះ [redacted] លីហួ ឈ្មោះ [redacted] រិទ្ធី និងឈ្មោះ [redacted] ជីវ៉ា។✓



Scanned with CamScanner

នៅថ្ងៃខែមិនចាំ ឆ្នាំ២០១២ ពេលព្រឹកយាយមិននៅផ្ទះ ចំណែកគាត់កំពុងដេកឈឺនៅបន្ទប់ក្រោយឈ្មោះ [redacted] លីហួ និង ឈ្មោះ [redacted] រិទ្ធី ទៅរៀនអស់ ប្អូនប្រុសរបស់ខ្លួនទៅលេងផ្ទះអ៊ុំ ពេលនោះឈ្មោះ [redacted] ជីវ៉ា បានលួងលោមខ្លួនថានាំទៅទិញនំ ហើយប្រាប់ខ្លួនឱ្យចូលបន្ទប់សិនចាំគាត់នាំទៅទិញនំ ហើយឈ្មោះ [redacted] ជីវ៉ា បានធ្វើសកម្មភាពដោះខោខ្លីខ្លួន ខ្លួនបានប្រាប់ថាម៉េចបានធ្វើអញ្ចឹងគាត់ឆ្លើយថាកុំមាត់ហើយខ្ទប់មាត់ខ្លួន ចាប់ដៃខ្លួនមិនឱ្យរើ និងបានដាក់ខ្លួនឱ្យដេកលើពូក បន្ទាប់មកគាត់បានស្រាតខោគាត់ហើយដេកលើខ្លួន និងបានយកប្រដាប់ភេទគាត់ដាក់ចូលប្រដាប់ភេទខ្លួនចូលតិចៗបានមួយសន្ទុះគាត់ក៏ចេញទឹកកាមប្រឡាក់ប្រដាប់ភេទខ្លួន ពេលនោះគាត់ក៏ឈប់ទៅ និងបាននិយាយគំរាមសម្លាប់ខ្លួនមិនឱ្យប្រាប់អ្នកណានោះទេ។ ពេលដែលឈ្មោះ [redacted] ជីវ៉ា ដាក់ចូលប្រដាប់ភេទចូលខ្លួននោះ ខ្លួនមានការឈឺតិចៗ។ ក្រោយមករំលងបានពីរទៅបីថ្ងៃគាត់ធ្វើអញ្ចឹងម្តងទៀតនៅក្នុងបន្ទប់ដដែល និងលើទីបីនៅក្នុងផ្ទះដែរ តែក្រៅបន្ទប់នៅពេលដែលយាយ និងបងប្អូនមិននៅផ្ទះដូចគ្នា បន្ទាប់មកនៅចុងឆ្នាំ២០១២ យាយបានលក់ផ្ទះនៅខេត្តព្រៃវែង ហើយមកទិញផ្ទះនៅភ្នំពេញវិញ។ នៅពេលយាយមិននៅផ្ទះខ្លួនកំពុងមើលទូរទស្សន៍នៅបន្ទប់ឡៅតឿ ស្រាប់តែឈ្មោះ [redacted] ជីវ៉ា បានចូលមកចាប់ស្រាតខោខ្លួន ចាប់ខ្ទប់មាត់ និងចាប់ដៃខ្លួន ហើយធ្វើសកម្មភាពរំលោភខ្លួនដោយយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួនញ៉ុលៗបានមួយសន្ទុះគាត់ក៏ឈប់ដោយមិនមានចេញទឹកកាមនោះទេ ហើយគាត់បានគំរាមខ្លួនមិនឱ្យប្រាប់អ្នកណានោះទេ។ ក្រោយមកឈ្មោះ [redacted] ជីវ៉ា បានទៅធ្វើការងារខាងក្រៅហើយដេកនៅកន្លែងធ្វើការងារយូរៗទើបមកផ្ទះម្តង លើកចុងក្រោយឈ្មោះ [redacted] ជីវ៉ា បានមកលេងផ្ទះយាយហើយយាយមិននៅផ្ទះ ពេលខ្លួនកំពុងដេកនៅបន្ទប់ឡៅតឿឈ្មោះ [redacted] ជីវ៉ា បានចូលមកធ្វើសកម្មភាពរំលោភខ្លួនដូចមុនទៀត។ រហូតដល់ខែធ្នូ ឆ្នាំ២០១២ ម្តាយខ្លួនបានមកពីប្រទេសថៃវិញ ហើយបាននាំខ្លួន និងប្អូនមករស់នៅជាមួយគាត់នៅបន្ទប់ជួលវិញរហូតដល់សព្វថ្ងៃ។ រហូតដល់អំឡុងឆ្នាំ២០១៣ ខ្លួនចាប់ផ្តើមធ្លាក់សតិចៗ ហើយនៅក្នុងឆ្នាំ២០២០ ម្តាយខ្លួនបានដឹងថាខ្លួនមានជម្ងឺធ្លាក់ស ម្តាយខ្លួនក៏តាមសួរខ្លួនរហូតទើបខ្លួនព្រមប្រាប់ថាបងជីដូនមួយឈ្មោះ [redacted] ជីវ៉ា ចាប់រំលោភខ្លួន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ បានឆ្លើយបានឆ្លើយនាពេលសវនាការថា ខ្លួនផ្ញើកូនជាមួយយាយក្នុងឆ្នាំ២០១២ និងយកកូនមកនៅជាមួយខ្លួនវិញក្នុងឆ្នាំ២០១៣ ខ្លួនបោកខោក្នុងឱ្យកូនស្រីឈ្មោះ [redacted] ម៉ូលីកា ឃើញខោក្នុងរបស់កូនប្លែកទើបសួរនាំគាត់ និងបានយកគាត់ទៅពិនិត្យនៅពេទ្យ។ ខ្លួនទើបដឹងក្នុងឆ្នាំ២០២០នេះទេ មូលហេតុដែលខ្លួនទើបដឹងដោយសារពីមុនខ្លួនមិនបានបោកខោអាវកូនទេ ទើបតែបោកខោអាវឱ្យកូនឃើញខោក្នុងរបស់កូនមានក្លិនស្អុយ និងធ្លាក់ស។ ខ្លួនយកប្តីក្រោយឆ្នាំ២០១៦ និងមានកូនជាមួយគ្នា២នាក់បន្ថែមទៀត ឪពុកចុងមិនដែលមានបញ្ហាជាមួយអ្នកផ្សេង ឬធ្វើអ្វីកូនទេ។

-អំណានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ នៅដំណាក់កាលស៊ើបសួរថា កាលពីអំឡុងដើមឆ្នាំ២០១២ ខ្លួនបានយកកូនឈ្មោះ [redacted] ម៉ូលីកា ភេទស្រី អាយុ ៧ឆ្នាំ និងឈ្មោះ [redacted] លីមហេង ភេទប្រុស អាយុ ៤ឆ្នាំ ទៅផ្ញើម្តាយបង្កើតខ្លួន ឈ្មោះ [redacted] ពាំងអួន នៅខេត្តព្រៃវែង ដោយខ្លួនបានលែងលះគ្នា ហើយខ្លួនត្រូវទៅធ្វើការងារនៅប្រទេសថៃ។ រហូតដល់ចុងឆ្នាំ២០១២ ខ្លួនបានមកពីប្រទេសថៃវិញ ហើយបាននាំកូនៗមករស់នៅជាមួយខ្លួននៅបន្ទប់ជួលវិញរហូតដល់សព្វថ្ងៃ។ រហូតដល់អំឡុងឆ្នាំ២០២០ នៅពេលខ្លួនយកខោរបស់កូនទៅបោកក៏ឃើញខោខ្លីរបស់កូនមានក្លិនស្អុយ និងធ្លាក់ស ហើយចេះតែសួរកូនដែរ ប៉ុន្តែកូនមិនប្រាប់រហូតខ្លួនតាមដានបានរយៈពេលពីរទៅបីខែខ្លួនក៏នាំកូនទៅពេទ្យហើយគ្រូពេទ្យប្រាប់ថាកូនរបស់ខ្លួនមិននៅក្រមុំទៀតទេ បន្ទាប់មកខ្លួនក៏លួងលោមសួរកូនរហូតទើបកូនប្រាប់ថាបងជីដូនមួយវាឈ្មោះ [redacted] ជីវ៉ា បានចាប់រំលោភវាចំនួនប្រាំដង នៅពេលដែលវារស់នៅជាមួយយាយ ខ្លួនក៏ដាក់ពាក្យបណ្តឹងតែម្តង។ ខ្លួនសំណូមពរឱ្យតុលាការផ្តន្ទាទោសឈ្មោះ [redacted] ជីវ៉ា តាមច្បាប់ និងទាមទារសំណងចំនួន ៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក។✓



Scanned with CamScanner

-លោកស្រីមេធាវី [redacted] ស៊ីណាកេត ជាមេធាវីការពារក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការកន្លងមកឃើញថាជនជាប់ចោទបានឆ្លើយសារភាពថាពិតជាបានរំលោភសេពសន្ថវៈទៅលើជនរងគ្រោះពិតប្រាកដមែន ហើយចម្លើយសារភាពរបស់ជនជាប់ចោទនេះក៏មានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយជនរងគ្រោះ ហើយក៏មានភាពស៊ីសង្វាក់គ្នាទៅនឹងលទ្ធផលកោសលវិច័យផងដែរ ដូច្នេះនៅក្នុងរឿងក្ដីនេះស្ថានភាពរបស់ជនជាប់ចោទគឺជាបទរំលោភសេពសន្ថវៈ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្ដន្ទាទោសជនល្មើសទៅតាមផ្លូវច្បាប់។ សូមបញ្ជាក់ជូនក្រុមប្រឹក្សាជំនុំជម្រះថា ទាក់ទងនឹងបទល្មើសរំលោភតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ គ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ ដូច្នេះសកម្មភាពរបស់ជនល្មើសថ្វីត្បិតតែគាត់បានសម្រេច ឬមិនបានសម្រេចក៏ដោយ មាត្រា២៣៩ មិនបានចែងថាទាល់តែការបញ្ចូលនោះគាត់បានសម្រេច ឬមិនបានសម្រេចទេ ឱ្យតែគាត់បានយកប្រដាប់ភេទគាត់បញ្ចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះគឺចាត់ទុកថាជាបទរំលោភហើយ ហើយធាតុផ្សំការប្រើអំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ឱកាស អញ្ចឹងហើយចម្លើយរបស់គាត់នៅមន្ត្រីនគរបាលយុត្តិធម៌គាត់បានគំរាមជនរងគ្រោះ ហើយគាត់បានយកប្រដាប់ភេទរបស់គាត់ដាក់បញ្ចូលដោយញុលៗចូលជ្រៅពាក់កណ្ដាលដែលគាត់បានបញ្ចូល ក្នុងនោះគេមិនបានចែងថា ចូលជ្រៅទើបជាបទល្មើសរំលោភទេ អញ្ចឹងគាត់បានបញ្ចូលហើយ តែញុលៗតែចូលរាក់ រហូតដល់តាមលទ្ធផលកោសលវិច័យថាគាត់មានស្នាមឆកទៅលើប្រដាប់ភេទរបស់ក្មេងស្រីនោះគឺជាបទល្មើសរំលោភហើយ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ឆ្លងតាមការដេញដោលនាពេលសវនាការ និងការពិនិត្យភស្តុតាងនានាក្នុងសំណុំរឿងតំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះពិតប្រាកដមែន ដូច្នេះតំណាងអយ្យការរក្សាការចោទប្រកាន់ និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្ដន្ទាទោសជនល្មើសទៅតាមផ្លូវច្បាប់។

-លោកមេធាវី [redacted] បញ្ញា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ជនជាប់ចោទនៅពេលដែលប្រព្រឹត្តបទល្មើសគឺជនជាប់ចោទនៅមានអាយុក្មេងខ្ចីនៅឡើយ ហើយជនជាប់ចោទក៏បានសារភាពតាំងពីចាប់ផ្ដើមសវនាការលើកទីមួយ និងលើកទីពីរនេះក៏ជនជាប់ចោទនៅតែទទួលស្គាល់ការពិតថាខ្លួនពិតជាបានប៉ះពាល់រូបរាងកាយរបស់ក្មេងស្រីរងគ្រោះមែន តែខ្លួនមិនបានយកប្រដាប់ភេទដាក់ចូលក្នុងប្រដាប់ភេទរបស់ក្មេងស្រីនោះទេ អង្គហេតុជាក់ស្ដែងបទល្មើសបានកើតឡើងកាលពីអំឡុងឆ្នាំ២០១២ ក៏ប៉ុន្តែលទ្ធផលកោសលវិច័យគឺត្រូវបានធ្វើឡើងក្នុងឆ្នាំ២០២០ អញ្ចឹងរយៈពេលនៃការធ្វើកោសលវិច័យគឺមានរយៈពេលវែងមែនទែនដែលយើងមិនអាចដឹងឱ្យជាក់លាក់ថាតើកុមារីនោះធ្លាប់មានប៉ះពាល់ជាមួយអ្នកណាទៀត យោងទៅតាមចម្លើយសារភាពរបស់ជនជាប់ចោទដែលទទួលស្គាល់នូវកំហុសរបស់ខ្លួន មានការសោកស្ដាយ ហើយចង់កែប្រែខ្លួនដើម្បីចូលរួមនៅក្នុងសង្គមវិញ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោសដល់ជនជាប់ចោទ។

-លោកមេធាវី [redacted] ឡុងឌី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ក្រោយពីបានស្ដាប់ការសាកសួរ និងក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់តំណាងអយ្យការ រួចមកឃើញថាកូនក្ដីរបស់ខ្លួនបានឆ្លើយសារភាព និងទទួលស្គាល់ថាគាត់បានប្រព្រឹត្តខុសពាក់ព័ន្ធទៅនឹងអំពើរំលោភទៅលើជនរងគ្រោះពិតមែនគឺបានប្រព្រឹត្តចំនួនបួនដង ក្នុងឆ្នាំ២០១១ ចំនួន៣ដង ឆ្នាំ២០១២ ចំនួន១ដង ចំពោះអំពើដែលគាត់ធ្វើនេះតាមចម្លើយរបស់គាត់គឺជាអំពើមួយដែលពុំទាន់បានសម្រេចចំណង់ផ្លូវភេទនៅឡើយទេ មានន័យថាគាត់យក



Scanned with CamScanner

ប្រដាប់ភេទគាត់ដាក់ទៅលើប្រដាប់ភេទរបស់ជនរងគ្រោះ តែពុំទាន់បានសម្រេចចំណង់ផ្លូវភេទគាត់នៅឡើយទេ ហើយឃើញថាអំពើដែលគាត់ធ្វើនេះគឺនៅក្នុងឆ្នាំ២០១១ ឆ្នាំ២០១២ ពេលនោះគាត់ទើបតែមានអាយុ ១៥ឆ្នាំ ១៦ឆ្នាំទេ ដូច្នេះការគិត ការពិចារណារបស់គាត់គឺពុំបានវែងឆ្ងាយទេ គួបផ្សំជាមួយការរៀនសូត្ររបស់គាត់ក៏ពុំបានជ្រៅជ្រះទៀត ទើបធ្វើឱ្យគាត់ពុំបានគិតវែងឆ្ងាយទើបប្រព្រឹត្តអំពើបែបនេះកើតឡើង ហើយឃើញថាលទ្ធផលកោសលវិច័យធ្វើក្នុងឆ្នាំ២០២០ ចំណែកអង្គហេតុកើតឡើងតាំងពីឆ្នាំ២០១១ តើរយៈពេល ៨ ទៅ ៩ឆ្នាំនេះ ថាតើលទ្ធផលនេះពិតទាំងអស់ទេ ប៉ុន្តែជាក់ស្តែងគាត់បានទទួលស្គាល់ថា បានធ្វើសកម្មភាពទៅលើជនរងគ្រោះពិតមែនគ្រាន់តែមិនបានសម្រេច ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យ និងពិចារណាផ្តល់នូវស្ថានសម្រាលឱ្យគាត់ដោយសារតែគាត់ជាប់ពន្ធនាគារជាច្រើនខែមកនេះ គាត់មានការភ្ញាក់ខ្លួន មានការដឹងខុស គាត់មានអារម្មណ៍ស្តាយក្រោយចំពោះទង្វើរបស់គាត់ គាត់មានចិត្តចេញទៅវិញចង់កែខ្លួន ណាមួយការប្រព្រឹត្តរបស់គាត់ ទើបជាលើកទីមួយទៀត ទោសពីមុនក៏ពុំធ្លាប់មានដែរ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តល់នូវស្ថានសម្រាលឱ្យគាត់ដោយយោងតាមមាត្រា១៦០ និងមាត្រា១៦៤ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា បាននិយាយសំដីចុងក្រោយបង្អស់ថា សំណូមពរសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនមានការស្តាយក្រោយចំពោះអំពើដែលខ្លួនបានប្រព្រឹត្តដោយរូបខ្លួនក៏មានកូនស្រីដូចគ្នា។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៧៥៤៧ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១៧៩១ "ភ" ដ.ដ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានបញ្ជូនជនជាប់ចោទ ៖

-ឈ្មោះ [redacted] ជីវ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ **រំលោភសេពសន្ថវៈអោនស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥។

២-តាមរបាយការណ៍សរុបលេខ០៧២/២០២០ រ.ប.ក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្សនៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានសន្និដ្ឋានបញ្ជាក់ថា ឈ្មោះ [redacted] ជីវ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តបទល្មើស រំលោភសេពសន្ថវៈទៅលើក្មេងស្រីរងគ្រោះឈ្មោះ [redacted] ម៉ូលីកា

ដែលមានអាយុ ០៨ឆ្នាំ កាលអំឡុងឆ្នាំ២០១២ ក្នុងគ្រាដែលរស់នៅជាមួយយាយនៅខេត្តព្រៃវែង និងបន្តធ្វើសកម្មភាពនៅរាជធានីភ្នំពេញ ប្រាកដមែន។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា បានឆ្លើយបដិសេធថា ខ្លួនពុំបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា ភេទស្រី អាយុ ០៨ឆ្នាំ កាលពីអំឡុងឆ្នាំ២០១២ នៅខេត្តព្រៃវែង និងឆ្នាំ២០១៥ នៅរាជធានីភ្នំពេញនោះទេ ខ្លួនគ្រាន់តែធ្វើសកម្មភាពទ្រោបពីលើជនរងគ្រោះ និងយកប្រដាប់ភេទរបស់ខ្លួនញលៗលើក្បាលពោះរបស់ក្មេងស្រី ដោយមិនបានដាក់ប្រដាប់ភេទរបស់ខ្លួនចូលទៅក្នុងប្រដាប់ភេទរបស់ក្មេងស្រីនោះទេ ប៉ុន្តែបើយោងតាមចម្លើយជនជាប់ចោទនៅដំណាក់កាលស៊ើបសួរ ចម្លើយជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារពិនិត្យការរំលោភផ្លូវភេទលេខ២៣/២១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋាន និងអនុសាសន៍ថា តាមការពិនិត្យសភាពរាងកាយទូទៅបង្ហាញឱ្យឃើញថា មានសភាពធម្មតា។ តាមការពិនិត្យប្រដាប់ភេទផ្នែកខាងក្រៅបង្ហាញឱ្យឃើញថា សន្ទះព្រហ្មចារីមានស្នាមឆកបន្តិចត្រង់ចំណុចម៉ោង៣"។ សន្និដ្ឋានតាមការពិនិត្យលើស្ត្រីរងគ្រោះបង្ហាញឱ្យឃើញថា សភាពរាងកាយទូទៅធម្មតា និងសភាពប្រដាប់ភេទផ្នែកខាងក្រៅមិនធម្មតា ដែលតុលាការអាចយកជាមូលដ្ឋានជឿជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

៤-សកម្មភាពរបស់ជនជាប់ចោទ ដែលបានរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា ដែលមានអាយុទើបតែ ០៨ឆ្នាំ ត្រូវបានច្បាប់កំណត់ថា ជាបទល្មើស រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយបញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី ៧(ប្រាំពីរ) ទៅ ១៥(ដប់ប្រាំ)ឆ្នាំ តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

៥-អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសីលធម៌ល្អក្នុងសង្គម ដែលច្បាប់បានហាមឃាត់ ជាពិសេសបំពានទៅនឹងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

៦-ក្នុងពេលប្រព្រឹត្តបទល្មើសឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា ស្ថិតក្នុងភាពជាអនីតិជននៅឡើយ ដូច្នេះតុលាការគប្បីលើកយកមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ មកអនុវត្តចំពោះអនីតិជនអាយុពី ១៤ឆ្នាំឡើងទៅ។ ក្នុងពេលប្រព្រឹត្តបទល្មើសឆ្នាំ២០១៥ ជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា ជានីតិជន ទោះបីជនជាប់ចោទជាអនីតិជន ឬនីតិជនតែជនជាប់ចោទមានស្មារតីគ្រប់គ្រាន់ និងយល់ដឹងអំពីអំពើប្រព្រឹត្តរបស់ខ្លួន ដូចនេះជនជាប់ចោទត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្ត។

៧-វត្ថុតាងមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ៧៥៤៧ រ.វ.ត ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាវត្ថុផ្ទាល់ខ្លួនមិនពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ គឺ: ទូរស័ព្ទដៃ ម៉ាកOPPO ពណ៌ខ្មៅ ចំនួន ០១(មួយ)គ្រឿង (មិនដំណើរការ)។

៨-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក ការទាមទារនេះ ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណារួចហើយ។

៩-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ពីបទ: រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌ



Scanned with CamScanner

ច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

១០-ការលើកឡើងរបស់តំណាងអយ្យការ ក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការដោយបានលើកឡើងពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ជីភ៌ា ពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ហើយស្នើសុំតម្កល់ការចោទប្រកាន់ និងសុំមកក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណាតាមច្បាប់នោះ យើងបានពិចារណារួចហើយ។

១១-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់នោះ ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណារួចហើយ។

១២-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការថាស្នើសុំឱ្យតុលាការផ្តល់នូវស្ថានសម្រាលទោសដល់កូនក្តីរបស់ខ្លួននោះ បញ្ហានេះក្រុមប្រឹក្សាជំនុំជម្រះបានពិចារណារួចហើយ។

១៣-តាមសំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ជីភ៌ា ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណារួចហើយ។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] ជីភ៌ា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិគ្រប់គ្រាន់) ដាក់ពន្ធនាគារកំណត់ ៧(ប្រាំពីរ)ឆ្នាំ គិតពីថ្ងៃបានឃុំខ្លួនបណ្តោះអាសន្នតទៅ ពីបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ជីភ៌ា សងសំណងជម្ងឺចិត្តចំនួន ២០,០០០,០០០(ម្ភៃលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ។

៣-ប្រគល់ឱ្យម្ចាស់ដើមវិញ ៖ ទូរស័ព្ទដៃម៉ាកOPPO ពណ៌ខ្មៅ ចំនួន ០១(មួយ)គ្រឿង។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ និងបន្តសវនាការ នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជីភ៌ា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៧រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner